ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ២៣៣ ព.ណ ប្រក

# ប្រកាស
## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
## របស់សាខាកាំកុងត្រូលរាជធានី-ខេត្ត

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ មាត្រា៤ និងបន្ថែមមាត្រា៨ស្ទួន នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ



ក

១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat
a, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469

-យោងលិខិតលេខ ១៨១១ មស.នក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ
-យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១**.- ត្រូវបានបង្កើតសាខាកាំកុងត្រូលរាជធានី-ខេត្ត ចំណុះឱ្យអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្ម ដែលមានភារកិច្ច ដូចខាងក្រោម ៖

- ផ្តល់សេវាត្រួតពិនិត្យទំនិញនាំចេញ នាំចូលរួមជាមួយស្ថាប័នគយ និងរដ្ឋាករផ្អែកលើកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ
- ធ្វើវិញ្ញាបនបត្រកម្ម ចំពោះទំនិញនាំចេញ តាមសំណើរបស់អ្នកស្នើសុំ ដើម្បីបំពេញល័ក្ខខ័ណ្ឌតម្រូវនៃប្រទេសនាំចូល
- ត្រួតពិនិត្យភាពអនុលោមតាមស្តង់ដារជាតិ នូវគុណភាព សុវត្ថិភាពផលិតផលទំនិញ ដែលមានប្រើសញ្ញាស្តង់ដារជាតិ
- សហការត្រួតពិនិត្យជាមុននូវប្រេតិវេទន៍ នៃផលិតផលទំនិញ ឬសេវាទាំងឡាយណា ដែលអាចប៉ះពាល់ដល់សុវត្ថិភាព សុខភាពនៃអ្នកប្រើប្រាស់ ឬផលិតកម្ម ឬពាណិជ្ជកម្ម នៃផលិតផលទំនិញ និងសេវាកម្ម ទាំងនោះដែលផ្តល់ដោយស្ថាប័នមានសមត្ថកិច្ច
- ត្រួតពិនិត្យផលិតផលទំនិញ និងសេវា ក្នុងតំណាក់កាលធ្វើចរាចរណ៍ពាណិជ្ជកម្មលើទីផ្សារ តាំងពិព័រណ៍ បង្ក្រាបការក្លែងបន្លំ និងប្រមូលកម្រៃសេវាត្រួតពិនិត្យទំនិញនាំចេញ-នាំចូល ដែលកំណត់ដោយប្រកាសរួមក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកដ្ឋានប្រគល់ឱ្យ ។

**ប្រការ ២**.- សាខាកាំកុងត្រូលថ្នាក់មូលដ្ឋាន រួមមាន ៖

- សាខាផែស្ងួតចុងទី-ភ្នំពេញ
- សាខាតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ
- សាខាអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
- សាខាអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ (កងកេង)
- សាខាខេត្តសៀមរាប និងអាកាសយានដ្ឋានអន្តរជាតិសៀមរាប
- សាខាខេត្តព្រះសីហនុ
- សាខាកំពង់ផែអន្តរជាតិភ្នំពេញ
- សាខារាជធានីភ្នំពេញ
- សាខាខេត្តកណ្តាល
- សាខាខេត្តព្រៃវែង
- សាខាខេត្តស្វាយរៀង
- សាខាខេត្តតាកែវ
- សាខាខេត្តកំពត-កែប
- សាខាខេត្តកំពង់ស្ពឺ
- សាខាខេត្តកោះកុង
- សាខាខេត្តកំពង់ឆ្នាំង



ក

- សាខាខេត្តពោធិ៍សាត់
- សាខាខេត្តបាត់ដំបង
- សាខាខេត្តបន្ទាយមានជ័យ
- សាខាខេត្តឧត្តរមានជ័យ
- សាខាខេត្តប៉ៃលិន
- សាខាខេត្តកំពង់ធំ
- សាខាខេត្តព្រះវិហារ
- សាខាខេត្តកំពង់ចាម
- សាខាខេត្តត្បូងឃ្មុំ
- សាខាខេត្តក្រចេះ
- សាខាខេត្តស្ទឹងត្រែង
- សាខាខេត្តមណ្ឌលគិរី
- សាខាខេត្តរតនគិរី

-ប៉ុស្តិ៍ ប៉ុស្តិ៍ផែ ប៉ុស្តិ៍ឃ្លាំងទំនិញ ប៉ុស្តិ៍ស្ថានីយ៍អ្នកដំណើរ ប៉ុស្តិ៍ផែអន្តរជាតិ ប៉ុស្តិ៍អន្តរជាតិ ប៉ុស្តិ៍តំបន់ ប៉ុស្តិ៍ព្រំដែន ប៉ុស្តិ៍ព្រំដែនអន្តរជាតិ ប៉ុស្តិ៍កំពង់ផែសមុទ្រ មជ្ឈមណ្ឌលត្រួតពិនិត្យ និងផែស្ងួត តាមអង្គការលេខ ជាឧបសម្ព័ន្ធភ្ជាប់ជាមួយ រួមនឹងសាខា ប៉ុស្តិ៍ ដែលមានបង្កើតថ្មីទៅតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**ប្រការ ៣.-** សាខាកាំកុងត្រូលរាជធានី-ខេត្ត ដឹកនាំដោយប្រធានសាខាមួយរូប មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានសាខាចំនួន ៣ (បី) រូប មានឋានៈស្មើ ប្រធានការិយាល័យថ្នាក់កណ្តាល ។ -ប៉ុស្តិ៍ មជ្ឈមណ្ឌលត្រួតពិនិត្យ និងផែស្ងួត ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើ ប្រធានការិយាល័យថ្នាក់កណ្តាល និងអមដោយអនុប្រធានមួយចំនួនតាមការចាំបាច់ មានឋានៈស្មើ អនុប្រធានការិយាល័យថ្នាក់កណ្តាល ។ ប្រធាន អនុប្រធានសាខា ប្រធាន អនុប្រធានប៉ុស្តិ៍ និងប្រធាន អនុប្រធានមជ្ឈមណ្ឌលត្រួតពិនិត្យ និងផែស្ងួត ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អនុលោមតាមអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែង ក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

**ប្រការ ៤.-** នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកកាំកុងត្រូល អគ្គនាយក អគ្គាធិការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

<u>ចំលងជូន៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៤ " ដើម្បីអនុវត្ត "
- ឯកសារ - កាលប្បវត្តិ